ធ៥-០១១-១៣៦ ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

**ជម្រាបមក**

**លោកនាយក សាខាធនាគារជាតិនៃកម្ពុជាខេត្ត**

**កម្មវត្ថុ** : ការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត

**យោង** : ចំណារឯកភាពរបស់ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបលោកនាយកសាខា ធនាគារជាតិនៃកម្ពុជាខេត្ត ឱ្យបានជ្រាបថា ដើម្បីជម្រុញ និងលើកទឹកចិត្តក្នុងការប្រើប្រាស់មូលប្បទានប័ត្រនៅតាមបណ្តាខេត្តឱ្យកាន់តែច្រើនថែមទៀតនោះ ធនាគារជាតិនៃកម្ពុជាបានធ្វើការកែសម្រួលការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ លើមូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ ២.០០០.០០០ រៀល ក្នុងមួយឆ្នាំដូចគ្នា។

កម្រៃសេវាប្រចាំឆ្នាំនេះ នឹងចាប់អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងធ្វើការជូនដំណឹងដល់សាខាធនាគារពាណិជ្ជជាសមាជិកសភាផាត់ទាត់ដើម្បីសហការអនុវត្ត។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយកបច្ចេកទេស**

**ឡូន សុខា**